ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សុន្ទរកថា

## ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សា

## ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

ក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង ស្តីពីការបង្កើត

មជ្ឈមណ្ឌលកសិកម្មអន្តរជាតិកូរ៉េ នៅកម្ពុជា

រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលអភិវឌ្ឍន៍ជនបទ

នៃសាធារណៈកូរ៉េ

ភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០១០

*- ឯកឧត្តម ច័ន្ទ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ*

*- ឯកឧត្តម លី យុង ស៊ូ ( Lee Kyong Soo ) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋកូរ៉េ*

*-ឯកឧត្តម គីម ហេស៊ូ (Kim, Jae Soo) ប្រធានរដ្ឋបាលអភិវឌ្ឍន៍ជនបទ នៃសាធារណៈ-រដ្ឋកូរ៉េ*

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ*

១- ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ប្រពៃ និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានមកចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង ស្តីពីការបង្កើតមជ្ឈមណ្ឌលកសិកម្មអន្តរជាតិកូរ៉េ នៅកម្ពុជា រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋបាលអភិវឌ្ឍន៍ជនបទ នៃសាធារណៈរដ្ឋកូរ៉េ ។ ក្នុងនាម **សម្តេចអគ្គមហា-**

**សេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការអបអរសាទរ និងគាំទ្រដល់កិច្ចចុះហត្ថលេខាលើអនុស្សារណៈនេះ នៅក្នុងពេលដែលរាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងយកចិត្តទុកដាក់ក្នុងការជំរុញកិច្ចអភិវឌ្ឍវិស័យកសិកម្ម ដោយសម្លឹងទៅរកការផ្គត់ផ្គង់ក្រៅប្រទេស ។ ពិធីចុះហត្ថលេខាអនុស្សារណៈនាពេលនេះ គឺជាសក្ខីភាពមួយ បញ្ជាក់យ៉ាងប្រត្យក្សនូវចំណងមិត្តភាព និង កិច្ចសហប្រតិបត្តិការដ៏ល្អប្រពៃរវាងប្រទេស និងប្រជាជនទាំងពីរ គឺព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋកូរ៉េ ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្សារភ្ជាប់ស្ពានមេត្រីភាពនេះ កាលពីឆ្នាំ១៩៩៧ ។ ដោយសារតែទំនាក់ទំនងការទូតយ៉ាងជិតស្និតរវាងប្រទេសយើងទាំងពីរ សាធារណរដ្ឋកូរ៉េបានក្លាយទៅជាប្រទេសដៃគូដ៏សំខាន់របស់កម្ពុជា លើវិស័យទេសចរណ៍ និងការវិនិយោគលើវិស័យនានាជាច្រើនទៀត ។

២- វិស័យកសិកម្មបានក្លាយទៅជាប្រភពដ៏សំខាន់មួយ ក្នុងការបង្កើនចំណូលដល់កសិករខ្មែរ ជាពិសេសគ្រួសារដែលក្រីក្រនៅតាមជនបទ ដោយបានរួមចំណែកកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ វិស័យនេះនៅតែមានតួនាទីដ៏លេចធ្លោ ក្នុងការផ្តល់ឱកាសការងារជិត ៨០ ភាគរយ នៃកម្លាំងពលកម្មសរុបក្នុងប្រទេស ។ ឈរលើស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៤ នៃ រដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានផ្តល់អាទិភាពខ្ពស់ដល់ការអភិវឌ្ឍន៍វិស័យកសិកម្ម ដែលជាសមាសភាគមួយដ៏សំខាន់នៃយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងធ្វើឱ្យប្រជាជនមានស្បៀងអាហារហូបគ្រប់គ្រាន់ និងរួមចំណែកជួយជំរុញឱ្យកំណើនសេដ្ឋកិច្ចមាននិរន្តរភាព ។ ថ្វីត្បិតតែវិស័យទេសចរណ៍ វិស័យកាត់ដេរ និងវិស័យសំណង់ បានទទួលរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក ផ្ទុយទៅវិញ វិស័យកសិកម្មនេះបានពង្រឹងតួនាទីរបស់ខ្លួន ក្នុងការជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចកម្ពុជា ដើម្បីឱ្យរាជរដ្ឋាភិបាលអាចសម្រេចបាននូវគោលដៅអភិវឌ្ឍប្រទេសជាតិ ស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២ ។

៣- រយៈពេលជាងដប់ឆ្នាំកន្លងទៅនេះ វិនិយោគទុនកូរ៉េមកកម្ពុជា ពាណិជ្ជកម្មកូរ៉េ-កម្ពុជា និងទេសចរណ៍កូរ៉េ បានហក់ឡើងខ្ពស់ហួសពីការស្មាន ដែលមានតម្លៃជាទឹកប្រាក់រាប់រយលានដុល្លា

សហរដ្ឋអាមេរិក នេះគឺជាការរួមចំណែកមួយ ដែលមិនអាចកាត់ថ្លៃបានរបស់ប្រជាជន និងរដ្ឋាភិបាលកូរ៉េ ក្នុងការស្តារនិងអភិវឌ្ឍប្រទេសកម្ពុជា ។ ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ដើម្បីរំលឹកជូនឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី មេត្តាជ្រាបនូវលទ្ធផលនៃព្រឹត្តិការណ៍ដ៏សំខាន់ក្នុងការបំពេញទស្សនៈកិច្ចជាផ្លូវរដ្ឋរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណៈកូរ៉េ កាលពីដើមខែមិថុនា ឆ្នាំ២០០៩ កន្លងទៅ គឺមានកិច្ចព្រមព្រៀង និងអនុស្សារណៈនៃការយោគយល់គ្នាចំនួន ០៧ ដែលត្រូវបានចុះហត្ថលេខាក្នុងអំឡុងពេលទស្សនកិច្ច ។ ក្នុងនោះ មានអនុស្សារណៈមួយ ស្តីពីកិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេសកសិកម្ម ត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តម ចាន់ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង **ឯកឧត្តម គីម ជេស៊ូ** **(Kim Jae-Soo)** ប្រធានរដ្ឋបាលអភិវឌ្ឍន៍ជនបទ នៃសាធារណរដ្ឋកូរ៉េ ។ តាមរយៈការចុះហត្ថលេខារួមគ្នាខាងលើនេះហើយ ដែលបានធ្វើឱ្យមានព្រឹត្តិការណ៍ដ៏អធិកអធមនាថ្ងៃនេះ ។

***- ឯកឧត្តម លោកជំទាវ លោក លោកស្រី***

៤- កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី ០៤ នៃរដ្ឋសភា គឺលើកស្ទួយវិស័យកសិកម្ម ដែលជាឆ្អឹងខ្នងដ៏រឹងមាំសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចជាតិ ហើយកាលពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០ កន្លងទៅថ្មីៗនេះ ក្នុងសន្និបាតចក្ខុវិស័យកម្ពុជា ឆ្នាំ២០១០ ស្តីពី " **ការវិលត្រឡប់រកកំណើនសេដ្ឋកិច្ចខ្ពស់ អាទិភាពនយោបាយ និងសកម្មភាព ដើម្បីកំណើន និងចីរភាពនៃការអភិវឌ្ឍ** " នៅវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ** បានមានប្រសាសន៍ប្រកបដោយសុទិដ្ឋិនិយមថា " **ភាពរឹងមាំនៃដំណើរការល្អក្នុងវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ បានជួយយើងឱ្យឆ្លងកាត់ពីវិបត្តិដោយពុំមានការខូតខាតអ្វីជាដុំកំភួនទេ ហើយយើងសង្ឃឹមថា វិស័យនេះនៅតែជាក្បាលម៉ាស៊ីនសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រក្នុងរយៈពេលវែងខាងមុខ** " ។

៥- ទស្សនវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលកម្ពុជា បានភ្ជាប់ជាមួយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍ ដោយក្នុងនោះការលើកស្ទួយវិស័យកសិកម្ម ជាជ្រុងមួយនៃយុទ្ធសាស្ត្រចតុកោណដើម្បីរួមចំណែកធានានិរន្តរភាពនៃការជំរុញកំណើនសេដ្ឋកិច្ចជាតិ ការបង្កើតការងារ សមធម៌ និង

ប្រសិទ្ធភាព ។ ក្នុងន័យនេះ ការអភិវឌ្ឍន៍វិស័យកសិកម្ម ឱ្យមានកម្រិតរីកចម្រើនប្រហាក់ប្រហែលនឹងបណ្ដាប្រទេសជឿនលឿនជិតខាង និងក្នុងតំបន់ ត្រូវតែជំរុញនិងផ្សារភ្ជាប់ការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាជាមូលដ្ឋាន ។ ត្រង់ចំណុចនេះ ខ្ញុំសូមគូសបញ្ជាក់ថា លទ្ធផលកំណើនវិស័យកសិកម្ម ដែលបានរៀបរាប់ខាងលើ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ គឺប្រាកដណាស់មានការរួមវិភាគទានដ៏ធំធេងនៃការងារសិក្សាស្រាវជ្រាវ និង ការអភិវឌ្ឍបច្ចេកវិទ្យាកសិកម្ម ហើយក្នុងន័យនេះ បានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធ ជាមួយនឹងទស្សនៈមួយដែលថែងថា : " **គ្មានការស្រាវជ្រាវ គឺគ្មានការអភិវឌ្ឍ** " ។

៦- ដូច្នេះ ពិធីចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀង ស្ដីពីការបង្កើតមជ្ឈមណ្ឌលកសិកម្មអន្តរជាតិកូរ៉េ នៅកម្ពុជា នាពេលនេះ គឺមានតម្លៃ និងមានអត្ថន័យធំធេងណាស់ ទាំងទិដ្ឋភាពសេដ្ឋកិច្ច និងនយោបាយ ក្នុងការជំរុញ និងបង្កើនសមត្ថភាពនៃការងារសិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាកសិកម្មឱ្យកាន់តែទូលំទូលាយ និងរីកចម្រើនរុងរឿង ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា ។ ជាថ្មីម្ដងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជននៃសាធារណរដ្ឋកូរ៉េ ដែលជានិច្ចជាកាលបានជួយឧបត្ថម្ភគាំទ្រដល់ប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចតេជោនាយករដ្ឋមន្ត្រី** ក្នុងដំណើរការស្ដារ និងអភិវឌ្ឍប្រទេសជាតិឡើងវិញ ។ ខ្ញុំសូមឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខិតខំពង្រឹងកិច្ចសហប្រតិបត្តិការឱ្យបានរលូន និងមានប្រសិទ្ធភាពខ្ពស់ ជាមួយនឹងរដ្ឋបាលអភិវឌ្ឍន៍ជនបទ របស់សាធារណរដ្ឋកូរ៉េ ហើយក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិនាពេលខាងមុខ ខ្ញុំសូមជូនពរឯកឧត្តមអគ្គរដ្ឋទូត ឯកឧត្តមរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ បានជួបប្រទះនូវព្រះពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ** !